**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៧៩៥ ព.ណ.ប្រកប

# ប្រកាស
# ស្តីពី
# ការបង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់ក្នុងការកសាងម៉ាកយីហោ និងគំនូរឧស្សាហកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ១.-**

បង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់ក្នុងការកសាងម៉ាកយីហោ និងគំនូរឧស្សាហកម្ម ដែលមានការិយាល័យនៅក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម និងមានសមាសភាព ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | អប់ វ៉ាឌី | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ប្រធាន |
| ២- | លោក | ឡៅ រាសី | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | អនុប្រធាន |
| ៣- | លោក | ឈាន ពិសិដ្ឋ | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | អនុប្រធាន |
| ៤- | លោក | រាម ច័ន្ទវណ្ណា | អគ្គនាយករង នៃអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យមនិងសិប្បកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៥- | លោក | ហ៊ីង ចក់ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ | សមាជិក |
| ៦- | លោក | ទុយ សារិន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន | សមាជិក |



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

| | | | |
|---|---|---|---|
| ៧- លោក | សុខ ហុង | ប្រធានការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ៨- លោក | ប៊ិន ចំរើនសត្យា | ប្រធានការិយាល័យ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | សមាជិក |
| ៩- លោក | ស្វាយ រិន | ប្រធានការិយាល័យ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | សមាជិក |
| ១០- លោកស្រី | ងួន ពៅលក្ខិណា | អនុប្រធានការិយាល័យ នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ | សមាជិក |
| ១១- លោក | សោម សែ | អនុប្រធានការិយាល័យ នាយកដ្ឋានអភិវឌ្ឍវិស័យឯកជន | សមាជិក |
| ១២- លោក | ឆោម ម៉ានិត | អនុប្រធានការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ នាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ១៣- លោក | យូ រ៉ាវុធ | អនុប្រធានការិយាល័យចុះបញ្ជីម៉ាក នាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ១៤- លោក | ឡូយ វិចិត្រា | អនុប្រធានការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិ នាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ១៥- លោក | សុខ វិបុល | អនុប្រធានការិយាល័យស្វ័យប្រវត្តិកម្ម និងព័ត៌មានវិទ្យា | សមាជិក |

**ប្រការ២.-**

មជ្ឈមណ្ឌលពិគ្រោះយោបល់នេះមានភារកិច្ចដូចតទៅ៖

- វិភាគអំពីតម្រូវការកម្មសិទ្ធិបញ្ញា និងសក្តានុពលរបស់អ្នកពាក់ព័ន្ធក្នុងស្រុកផ្សេងៗដែលរួមមាន៖ ក្រុមហ៊ុន សមាគមអាជីវកម្ម សហករណ៍។ល។
- ផ្តល់នូវការណែនាំលើផ្នែកយុទ្ធសាស្ត្រដែលសមស្របស្តីពីការកសាងម៉ាកយីហោដែលពាក់ព័ន្ធ នឹងកម្មសិទ្ធិបញ្ញាដែលរាប់បញ្ចូលទាំងការបង្កើតម៉ូដែលអាជីវកម្ម ការធ្វើអាជីវកម្ម និងកិច្ចការពារម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម គំនូរឧស្សាហកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងឈ្មោះ Domain ។ល។
- ជួយសម្របសម្រួលដល់ការដាក់ពាក្យស្នើសុំចុះបញ្ជីកម្មសិទ្ធិបញ្ញាក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិរបស់អ្នកពាក់ព័ន្ធក្នុងស្រុក
- ផ្តល់សេវាប្រឹក្សាយោបល់ផ្សេងៗ លើការកសាងម៉ាកយីហោដែលមិនពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដូចជាផ្នែកទីផ្សារ និងការផ្សាយពាណិជ្ជកម្មគ្រប់ទម្រង់ដែលរាប់បញ្ចូលតាមរយៈប្រព័ន្ធឌីជីថល សំបកវេចខ្ចប់ យុទ្ធសាស្ត្រសមាហរណកម្ម ការបង្កើតគេហទំព័រ ការប្រើប្រាស់ជាយុទ្ធសាស្ត្រនៃប្រព័ន្ធផ្សព្វផ្សាយ។ល។
- លើកស្ទួយសហគ្រាសធុនតូច និងមធ្យមប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីទ្រទ្រង់អាជីវកម្មរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើង។
- អនុវត្តគំនិតផ្តួចផ្តើមលើកកម្ពស់ការយល់ដឹងជាសាធារណៈ ផ្តល់នូវវគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាព ដើម្បីផលប្រយោជន៍របស់អ្នកពាក់ព័ន្ធក្នុងស្រុក។

**ប្រការ៣.-**

សមាជិកនៃមជ្ឈមណ្ឌលពិគ្រោះយោបល់នេះ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន តាមការចាំបាច់។

**ប្រការ៤.-**

តាមការចាំបាច់ ប្រធានមជ្ឈមណ្ឌលពិគ្រោះយោបល់នេះ អាចអញ្ជើញភាគីពាក់ព័ន្ធ និងវិស័យឯកជនមកចូលរួមសិក្ខាសាលា កិច្ចប្រជុំ និងដាក់ចេញផែនការសកម្មភាពអនុវត្តផ្សេងៗ។

**ប្រការ៥.-**

សមាសភាពមជ្ឈមណ្ឌលពិគ្រោះយោបល់នេះ អាចមានការកែសម្រួលឡើងវិញតាមការចាត់តាំងជាថ្មីរបស់ក្រសួង-ស្ថាប័នសាមី។

**ប្រការ៦.-**

ក្នុងករណីប្រធានមានភារកិច្ចផ្សេង អនុប្រធានអាចដឹកនាំកិច្ចប្រជុំផ្សេងៗ បានតាមការប្រគល់សិទ្ធិរបស់ប្រធាន។ មជ្ឈមណ្ឌលពិគ្រោះយោបល់នេះត្រូវជួបប្រជុំរៀងរាល់០៦ខែម្តង ឬច្រើនជាងនេះតាមការចាំបាច់។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

<u>**កន្លែងទទួល៖**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ ៧
- ឯកសារ កាលប្បវត្តិ

# MEMBER OF CAMBODIA BRANDING BUREAU

## The Department of Intellectual Property, Ministry of Commerce

| No. | Name | Sex | Ministry/Institute | Email | Telephone |
|---|---|---|---|---|---|
| 1 | Op Rady | M | Director of DIP, MoC | oprady@yahoo.com | (+855-11) 888 969 |
| 2 | Lao Reasey | M | Deputy Director of DIP, MoC | reasey_pp34@yahoo.com | (+855-12) 807 346 |
| 3 | Chhean Piseth | M | Deputy Director of MIH | chheanpiseth@yahoo.com | (+855-12) 519 659 |
| 4 | Ream Chan Vanna | M | Deputy Director of General of SMES, MIH | chanbanna@hotmail.com | (+855-12 878 356) |
| 5 | Hoeung Chak | M | Deputy Director of Department of Market Development, MoC | | |
| 6 | Sok Hong | M | Bureau Chief of GIs and TS | sokhong01@gmail.com | (+855-12) 378 680 |
| 7 | Bin Charoeun Sathya | M | Chief of Design Bureau, DIP, MIH | sathyamoc@gmail.com | (+855-97) 622 2206 |
| 8 | Svay Rien | M | Chief of Patent Bureau, DIP, MIH | Rein_bbu@yahoo.com | (+855-12) 982 382 |
| 9 | Tuy Sarin | M | Deputy chief Bureau of Private Sector Development, MoC | Tuysarin90@gmail.com | (+855-12) 831 632 |
| 10 | Nguon Pov Leakena | F | Deputy Chief Bureau, Department of Market Development, MoC | Leakena.ngoun@gmail.com | (+855-12) 972 316 |
| 11 | Som Se | M | Deputy Chief Bureau, Department of Private Sector Development, MoC | som.se@moc.gov.kh | (+855-99) 962 461 |

| | | | | | |
|---|---|---|---|---|---|
| 12 | Chhom Manith | M | Deputy Chief Bureau of GI and TS, DIP, MoC | manithgi@gmail.com | (+855-12) 456 588 |
| 13 | You Ravuth | M | Deputy Chief Bureau of Trade Marks Registration, DIP, MoC | youravuth@yahoo.com | (+855-12) 501 559 |
| 14 | Loy Vichetra | M | Deputy Chief Bureau of International Trade Marks Registration, DIP, MoC | vichetrakh@yahoo.com | (+855-95) 333 231 |
| 15 | Sok Vibol | M | Deputy Chief Bureau of Automation and Information Technology, DIP, MoC | moc.vibol@yahoo.com | (+855-12) 491 871 |
| 16 | Mann Mliss | F | Deputy Chief Bureau of Department of Market Development, DIP, MoC | mannmliss@gmail.com | (+855-99) 954 565 |
| 17 | Oddam Heng | M | Deputy Chief Bureau, DIP, MIH | oddomheng@yahoo.com | (+855-12) 696 260 |
| 18 | Eang Phallin | F | Official, International Trade Marks Registration, DIP, MoC | phallineang1991@gmail.com | (+855-81) 598 802 |